-8-

ព្រះរាជាណាចក្រ កម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

តុលាការកំពូល

សភាផ្នែក រដ្ឋប្បវេណី

---

សំណុំរឿង រដ្ឋប្បវេណី

លេខ ៖ ២១៩

ចុះថ្ងៃទី១៨ខែតុលាឆ្នាំ១៩៩៦

សាលដីកា

លេខ ៖ ១៣ ពរ-ភ-

ចុះថ្ងៃទី១០ខែសីហាឆ្នាំ១៩៩៩

## ក្នុងនាមប្រជារាស្ត្រខ្មែរ

## តុលាការកំពូល

បានបើកសវនាការជាសាធារណៈ នៅថ្ងៃទី ១០ ខែ សីហា ឆ្នាំ ១៩៩៩ ដោយមានសមាសភាពក្រុមប្រឹក្សាជំនុំជម្រះដូចតទៅ ៖

១ - ឯកឧត្តម ឌិត មុន្ទី ប្រធាន
២ - លោក ម៉ែន ស៊ិន ចៅក្រម
៣ - លោក ទៀល មួន ចៅក្រម
៤ - លោក អ៊ឹម ស៊ីផល ចៅក្រម
៥ - លោក សោម សិរីវឌ្ឍ ចៅក្រម
៦ - លោក ស៊ិន នឹម ចៅក្រម
៧ - លោក ជីវ កេង ចៅក្រម
៨ - លោក ព្រាក់ គឹមសាន ចៅក្រម
៩ - លោក យស់ សុខឿន ចៅក្រម

ក្រឡាបញ្ជី

លោក ជេត ច័ន្ទថា

តំណាងមហាអយ្យការ

លោក សាយ សារី ជាព្រះរាជអាជ្ញា

ដើម្បីជំនុំជម្រះលើបណ្តឹងសាទុក្ខពីសាលដីការដ្ឋប្បវេណីលេខ ២៦២ ចុះថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ១៩៩៦ នៃសំណុំរឿងរដ្ឋប្បវេណីលេខ ១៤ ចុះថ្ងៃទី ១៣ ខែ កុម្ភៈ ឆ្នាំ ១៩៩៦ ។

រវាងម្ចាស់បណ្តឹងសាទុក្ខឈ្មោះ ង៉ូ នុន ភេទប្រុស អាយុ ៥៤ ឆ្នាំ ជាតិ ខ្មែរ មុខរបរ បុគ្គលិកសាលាខេត្ត មានទីលំនៅសព្វថ្ងៃ ភូមិទី ៦ សង្កាត់លេខ ១ ទីរួមខេត្តស្វាយរៀង ។ ឪពុកឈ្មោះ យោក យូ "ស" ម្តាយឈ្មោះ សូ អ៊ុត "ស" ប្រពន្ធឈ្មោះ អ៊ុង អាន ។

និងចុងបណ្តឹងសាទុក្ខឈ្មោះ អ៊ុក សុភាព ភេទប្រុស អាយុ ៣២ ឆ្នាំ ជាតិ ខ្មែរ

ប្រាក់នៅសល់ពីការចំណាយ " គ្មាន " ។ កាលបើអ្នកឧទ្ធរណ៍ត្រូវបង្គាប់អោយឈ្មោះនេះសងប្រាក់ ៧.០០០៛ ទៅដើមចោទវិញ និង អោយបង់ពន្ធមាមាត្រ : ២.៦០៣,៣៥៛ បន្ថែមទៀត ដែលត្រូវបង់ចូលថវិការដ្ឋ ២.០៨៣,០៨៛ និង ពន្ធជារង្វាន់ក្រឡាបញ្ជីក្នុងព្រះរាជាណាចក្រកម្ពុជា ៥២០,៧៧៛ ។ ពន្ធមាមាត្រនេះត្រូវអោយដើមចោទបង់ទុកជាមុនដែរ ទើបបង្គាប់អោយចុងចម្លើយសងទៅដើមចោទវិញជាក្រោយ ។

តាមសារាចរលេខ ០៣ ស.រ ៦១៣_៨៨ ចុះថ្ងៃទី ២៧.៤.៨៨ របស់ក្រសួងយុត្តិធម៌ ស្តីពីសេចក្តីណែនាំអំពីគោលការណ៍សំរាប់ជំនុំជំរះវិវាទទាក់ទងនឹងសិទ្ធិលើកម្មសិទ្ធិ និង មាត្រា ៥ មាត្រា៧ មាត្រា ៨ មាត្រា ១០ មាត្រា ១១ មាត្រា ១២ មាត្រា ១៣ មាត្រា ១៤ មាត្រា ១៦ នៃច្បាប់ស្តីពីប្រាក់ប្រដាប់ក្តី ។

៥ - សាលក្រមនេះជំនុំជំរះជាសាធារណៈចំពោះមុខគូក្តី បើគូក្តីណាមិនសុខចិត្តទេនោះ មានសិទ្ធិប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់ ។

បានឃើញបណ្តឹងឧទ្ធរណ៍លេខ ០៣ ចុះថ្ងៃទី ០២ ខែ មិថុនា ឆ្នាំ ១៩៨៤ របស់ឈ្មោះ - លោក អ៊ុក សុភាព ប្តឹងមិនសុខចិត្តនឹងសេចក្តីសំរេចនៃសាលក្រមទាំងមូល ។

បានឃើញសាលដីការជួបប្រជុំលេខ ៥៩ ចុះថ្ងៃទី ១៣ ខែ កុម្ភៈ ឆ្នាំ ១៩៨៥ របស់ - សាលាឧទ្ធរណ៍ដែលមានខ្លឹមសារនៃសេចក្តីសំរេចដូចតទៅ :

១ - ទទួលបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ ១៩៨៤ របស់ឈ្មោះ អ៊ុក សុភាព ទុកជាត្រឹមត្រូវតាមទំរង់ និង គតិច្បាប់ ។

២ - បដិសេធប័ណ្ណសំគាល់សិទ្ធិលេខ អា១_០២០៩ ចុះថ្ងៃទី ០៦.៥.៩២ ដែលមានម្ចាស់ឈ្មោះ យូ រុន ចោលជាអសារបង់ ។

៣ - បដិសេធសាលក្រមលេខ ២២ ចុះថ្ងៃទី ២៩.៤.៨៤ របស់តុលាការខេត្តស្វាយរៀង ចោលជាអសារបង់ ។

៤ - ប្រគល់ដីទំនាស់ទំហំ ១៧៣,៥៩ ម៉ែត្រក្រឡា អោយទៅឈ្មោះ អ៊ុក សុភាព កាន់កាប់ជាកម្មសិទ្ធិចាប់ពីពេលដែលសាលដីកានេះមានអានុភាពអនុវត្តតទៅ ។

៥ - បង្គាប់អោយឈ្មោះ យូ រុន បង់ប្រាក់ប្រដាប់ក្តីនៅជាន់សាលាឧទ្ធរណ៍ ១៣.០០០រៀល ប្រាក់នេះឈ្មោះ អ៊ុក សុភាព បានបង់រួចហើយ ហើយអោយឈ្មោះ យូ រុន សងទៅឈ្មោះ អ៊ុក សុភាព វិញ នៅពេលដែលសាលដីកានេះមានអានុភាពអនុវត្ត កាលបើផុតកំណត់ប្តឹងសាទុក្ខ បង្គាប់អោយឈ្មោះ យូ រុន បង់ពន្ធសមាមាត្រមួយភាគរយលើតម្លៃដីទាស់ ប្រាក់នេះ ៨០ ភាគរយបានជាប្រយោជន៍ដល់ថវិកាជាតិ ២០ ភាគរយសំរាប់ប្រាក់ក្រឡាបញ្ជីទូទាំងប្រទេស ។

សាលដីកានេះប្រកាសជាសាធារណៈចំពោះមុខគូក្តី សម្រេចបើកផ្លូវប្តឹងសាទុក្ខរយៈពេល ពីរខែ គិតចាប់ពីថ្ងៃនេះតទៅ ។

បានឃើញបណ្តឹងសាទុក្ខលេខ ៤៨ ចុះថ្ងៃទី ២៧ ខែ កុម្ភៈ ឆ្នាំ ១៩៨៥ របស់ឈ្មោះ យូ រុន

ប្តឹងមិនសុខចិត្តនឹងសេចក្តីសំរេចរបស់សាលាឧទ្ធរណ៍ទាំងមូល ។

បានឃើញសាលដីការបស់តុលាការកំពូលលេខ ១៥០ ចុះថ្ងៃទី ២៨ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ ដែលមានខ្លឹមសារនៃសេចក្តីសំរេចដូចតទៅ :

១ - ទទួលបណ្តឹងសាទុក្ខលេខ ៤៨ ចុះថ្ងៃទី ២៧ ខែ កុម្ភៈ ឆ្នាំ ១៩៩៥ របស់ឈ្មោះ - ឈូ រុន ទុកជាត្រឹមត្រូវតាមទំរង់ និង គតិច្បាប់ ។

២ - ទុកជាមោឃៈសាលដីការដ្ឋប្បវេណីលេខ ៥៩ ចុះថ្ងៃទី ១៣ ខែ កុម្ភៈ ឆ្នាំ ១៩៩៥ របស់សាលាឧទ្ធរណ៍ទាំងមូល ។

៣ - បង្វិលសំណុំរឿងរដ្ឋប្បវេណីលេខ ១០០ ចុះថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ១៩៩៥ របស់តុលាការកំពូលទៅសាលាឧទ្ធរណ៍ដើម្បីជំនុំជំរះជាថ្មីរឿងវិញ ។

៤ - រឹបអូសប្រាក់ប្រដាប់ក្តីដែលឈ្មោះ ឈូ រុន បានបង់នៅតុលាការកំពូលចំនួន ១៩០០០ រៀល គឺ :

- ពន្ធចុះបញ្ជីក្តី និង ពន្ធហ៊ីង ៤.០០០៛ ប៉ុន្តែប្រាក់នេះត្រូវដក ៨០០រៀល ជារង្វាន់ក្រឡាបញ្ជីការចិតប្រាក់

- ចំណាយលើកិច្ចប្រគល់ដីកាកោះ ១២.០០០ រៀល សរុប ១៦.០០០ រៀល នៅសល់ ៣.០០០ រៀល ប្រគល់អោយម្ចាស់ដើមវិញ ហើយតម្រូវអោយឈ្មោះ អ៊ុក សុភាព សងប្រាក់ចំនួន ១៦.០០០ រៀល ទៅឈ្មោះ ឈូ រុន វិញ ។

៥ - សាលដីកានេះប្រកាសនាសវនាការជាសាធារណៈនៅថ្ងៃទី២៨ខែវិច្ឆិកាឆ្នាំ១៩៩៥។

បានឃើញសាលដីកាលេខ ២៦២ ចុះថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ១៩៩៦ របស់សាលាឧទ្ធរណ៍ ដែលមានខ្លឹមសារនៃសេចក្តីសំរេចដូចតទៅ :

១ - ទទួលជំនុំជំរះរឿងក្តីលេខ ១៤ ចុះថ្ងៃទី ១៣ ខែ កុម្ភៈ ឆ្នាំ ១៩៩៦ បានដោយអំណាចសាលដីកាតុលាការកំពូលលេខ ១៥០ ចុះថ្ងៃទី ២៨ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ ។

២ - តម្កល់សាលដីការដ្ឋប្បវេណីលេខ ៥៩ ចុះថ្ងៃទី ១៣ ខែ កុម្ភៈ ឆ្នាំ ១៩៩៥ របស់សាលាឧទ្ធរណ៍ទុកជាបានការពេញទាំងមូល ។

៣ - សាលដីកានេះជំនុំជំរះ និង ប្រកាសជាសាធារណៈចំពោះមុខគូក្តី ។ សិទ្ធិបើកផ្លូវប្តឹងសាទុក្ខក្នុងកំណត់ច្បាប់ ។

បានឃើញបណ្តឹងសាទុក្ខលើកទី ២ លេខ ១៧០ ចុះថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ១៩៩៦ របស់ឈ្មោះ ឈូ រុន ប្តឹងមិនសុខចិត្តលើខ្លឹមសារនៃសេចក្តីសំរេចទាំងមូល នៃសាលដីការដ្ឋប្បវេណីលេខ ២៦២ ចុះថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ១៩៩៦ របស់សាលាឧទ្ធរណ៍ ។

បានឃើញសារណាការពារ ចុះថ្ងៃទី ០២ ខែ ធ្នូ ឆ្នាំ ១៩៩៦ របស់ឈ្មោះ ឈូ រុន ជាម្ចាស់បណ្តឹងសាទុក្ខ ។

បានឃើញសារណាតប ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ១៩៩៦ របស់ឈ្មោះ អ៊ុក សុភាព ជាចុងបណ្តឹងសាទុក្ខ ។

បានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

បានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ ថា

- សាលដីការបស់សាលាឧទ្ធរណ៍សំរេចស្របនឹងគតិច្បាប់ហើយ ។
- សូមក្រុមប្រឹក្សាជំនុំជំរះសំរេចតាមច្បាប់ ។

បានស្តាប់ចម្លើយរបស់ឈ្មោះ យូ រុន ជាដើមចោទ និង ជាដើមបណ្តឹងសាទុក្ខ នៅពេលជំនុំជំរះបានឆ្លើយបញ្ជាក់ថា បានជាខ្លួនប្តឹងសាទុក្ខព្រោះថា ខ្លួនធ្លាប់កាន់កាប់ដីចំនាស់នេះតាំងពីឆ្នាំ ១៩៨៧ ដោយខ្លួនបានទិញពីឈ្មោះ ម៉ុក ប៊ុន ក្នុងតម្លៃ ២.០០០ រៀល ហើយនៅឆ្នាំ ១៩៨៩ ឈ្មោះ អ៊ុក សុភាព បានមកសុំខ្លួនស្នាក់នៅជាបណ្តោះអាសន្ន ។ បើឈ្មោះ អ៊ុក សុភាព ទិញដីនេះ ខ្លួនលក់តម្លៃតែបីដីប៉ុណ្ណោះ ។

បានស្តាប់ចម្លើយរបស់ឈ្មោះ អ៊ុក សុភាព ជាចុងចម្លើយ និង ជាចុងបណ្តឹងសាទុក្ខ នៅពេលជំនុំជំរះបានឆ្លើយបញ្ជាក់ថា ខ្លួនបានទិញដីនេះពីឈ្មោះ ម៉ុក ប៊ុន ក្នុងតម្លៃ ២.០០០ រៀល ដោយអោយលុយទៅឈ្មោះ យូ រុន យកទៅប្រគល់អោយឈ្មោះ ម៉ុក ប៊ុន ។ ឈ្មោះ យូ រុន ពុំបានមកទិញដីនេះនៅឆ្នាំ ១៩៨៧ នោះទេ ។ ដីចំនាស់នេះមានតម្លៃប្រហែលជាពីរទៅបីតម្លឹងមាស ។

- ក្រោយពីបានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ
- ក្រោយពីបានស្តាប់ចម្លើយដោះសាររបស់គូភាគី
- ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

## តុលាការកំពូល

- យល់ឃើញថា បណ្តឹងសាទុក្ខលេខ ១៧០ ចុះថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ១៩៩៦ របស់លោក យូ រុន ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើករឿងនេះមកជំនុំជំរះដល់អង្គសេចក្តីបាន តាមមាត្រា ១៤ នៃច្បាប់ស្តីពីការចាត់តាំង និង សកម្មភាពរបស់សាលាជំរះក្តី និង មាត្រា ២២៦ នៃច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ ។

- យល់ឃើញថា ការដែលសាលាឧទ្ធរណ៍សំរេចតម្កល់សាលដីការដ្ឋប្បវេណីលេខ ៥៨ ចុះថ្ងៃទី១៣ ខែ កុម្ភៈ ឆ្នាំ ១៩៩៥ របស់ខ្លួននោះជាការពុំត្រឹមត្រូវទេ ព្រោះថា សាលដីកានេះត្រូវបានតុលាការកំពូលទុកជាមោឃៈតាមសាលដីការដ្ឋប្បវេណីលេខ ១៥០ ចុះថ្ងៃទី ២៨ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ រួចហើយ ដូច្នេះការសំរេចនេះធ្វើឡើងខុសនឹងទំរង់ច្បាប់ ។

- យល់ឃើញថា ការដែលសាលាឧទ្ធរណ៍សំរេចតម្កល់សាលដីការដ្ឋប្បវេណីលេខ ៥៨ ចុះថ្ងៃទី ១៣ ខែ កុម្ភៈ ឆ្នាំ ១៩៩៥ របស់ខ្លួន ដែលសំរេចប្រគល់ដីចំនាស់អោយលោក អ៊ុក សុភាព ដោយ

កុំមានតម្លៃតបស្នងនោះជាការភ័ន្តច្រឡំ ព្រោះថា លោក ឈូ រុន ពិតជាបានទិញដីទំនាស់នេះពីឈ្មោះ ម៉ុក ប៊ុន និងប្រពន្ធឈ្មោះ កែន ភុន ក្នុងតម្លៃ ២.០០០ រៀល កាលពីឆ្នាំ ១៩៨៧ ដោយលោក ម៉ុក ប៊ុន និង ប្រពន្ធ ទទួលស្គាល់ថា លោក ឈូ រុន ពិតជាបានទិញដីនេះមែន ប៉ុន្តែសំរាប់អោយលោក អ៊ុក សុភាព ជាកូនស្នាក់នៅ ។ ទន្ទឹមនឹងនេះក៏មានកំណត់ហេតុ លិខិតប្រគល់ និង ទទួលប្រាក់លេខ ១៧៣៨ ចុះថ្ងៃទី ១២ ខែ ធ្នូ ឆ្នាំ ១៩៨៩ របស់គណៈកម្មាធិការទីរួមខេត្តបញ្ជាក់ពីការទិញ និង បំណងនៃការទិញនេះថែមទៀតផង ។

- យល់ឃើញថា លោក អ៊ុក សុភាព បានចាក់ដីបំពេញ និង បានធ្វើផ្ទះរស់នៅជាប់ជាប្រចាំលើដីទំនាស់នេះតាំងពីឆ្នាំ ១៩៨៩ រហូតមកដល់ ដូចេ្នះតុលាការកំពូលគប្បីពិចារណាអំពីការស្នាក់នៅនេះ ។

- យល់ឃើញថា នៅក្នុងកំណត់ហេតុផ្សះផ្សាសិរីសុំសួលចុះថ្ងៃទី ០៧ ខែ ឧសភា ឆ្នាំ១៩៩៥ នៅតុលាការកំពូល លោក ឈូ រុន ក្តី លោក អ៊ុក សុភាព ក្តី សុទ្ធតែបានបញ្ជាក់រៀងៗខ្លួន អំពីតម្លៃដីទំនាស់ ហើយនឹងសំណូមពរដែលចង់បញ្ចប់រឿងក្តីនេះដោយការចេញប្រាក់ថ្លៃដីទំនាស់ពីភាគីម្ខាងទៀតមកអោយខ្លួន ហើយដែលបញ្ហានេះតុលាការកំពូលត្រូវពិចារណាតាមលក្ខណៈសមធម៌ ។

- យល់ឃើញថា សាលដីការដ្ឋប្បវេណីលេខ ២៦២ ចុះថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ១៩៩៦ របស់សាលាឧទ្ធរណ៍ដែលបានសំរេចសេចក្តីខាងនេះមានការខុសឆ្គងទាំងទំរង់ ទាំងគតិច្បាប់ ។

ហេតុដូច្នេះ

វិនិច្ឆ័យសេចក្តី ចំពោះមុខតូក្តី

១ - ទទួលបណ្តឹងសាទុក្ខលេខ ១៧០ ចុះថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ១៩៩៦ របស់លោក ឈូ រុន ទុកជាត្រឹមត្រូវតាមទំរង់ និង គតិច្បាប់ ។

២ - ទុកជាមោឃៈសាលដីការដ្ឋប្បវេណីលេខ ២៦២ ចុះថ្ងៃទី ១៨ ខែ កក្កដាឆ្នាំ១៩៩៦ របស់សាលាឧទ្ធរណ៍ទាំងមូល ។

៣ - ប្រគល់ដីទំនាស់ទំហំ ១៧៣,៥៧ ម៉ែត្រក្រឡា ស្ថិតនៅភូមិទី ៦ សង្កាត់លេខ ១ ទីរួមខេត្តស្វាយរៀង មានព្រំប្រទល់ខាងជើងទល់នឹងឈ្មោះ ឈូ រុន , ខាងត្បូងទល់នឹងផ្លូវច្រក , ខាងកើតទល់នឹងផ្លូវច្រក , ខាងលិចទល់នឹងឈ្មោះ កែន សាន អោយទៅលោក អ៊ុក សុភាព កាន់កាប់គ្រប់គ្រងតទៅ ។

៤ - បង្គាប់អោយលោក អ៊ុក សុភាព ប្រគល់មាសទឹកដប់ចំនួនបីជីអោយទៅលោក ឈូ រុន ជាថ្នូរនឹងដីទំនាស់ ។

៥ - រឹបអូសប្រាក់ប្រដាប់ក្តីដាក់តុលាការកំពូលចំនួន ១៩.០០០រៀល ដែលលោក ឈូ រុន

ពន្ធបង់ទុកជាមុន គឺ :

- ពន្ធចុះបញ្ជីក្តី និង ពន្ធ ត្រឹងចំនួន ៥.០០០ រៀល ប៉ុន្តែប្រាក់នេះត្រូវកាត់ចំនួន - ៨០០ រៀល សំរាប់ជារង្វាន់ក្រឡាបញ្ជីការពិនិត្យប្រាក់ ។

- ចំណាយលើកិច្ចប្រគល់ដីការកោះចំនួន ១៣.០០០ រៀល សរុប ១៨.០០០ រៀល ហើយ ត្រូវអោយលោក អ៊ុក ស្មាត ដាក់ប្រាក់ចំនួន ១៨.០០០ រៀលនេះទៅលោក ... ទុក - វិញ ។

បន្ទាប់ពីលោក អ៊ុក ស្មាត បង់ពន្ធទាំងនេះត្រូវបានកាត់ក្តីរឿងនេះនៅថ្ងៃទី ។ ៦ - ... នៅថ្ងៃទី ១០ ខែ មីនា ឆ្នាំ ១៩៥៥ ។

មុខរបរ ធ្វើការនៅមន្ទីរឧស្សាហកម្មខេត្ត មានទីលំនៅសព្វថ្ងៃ ភូមិទី ៦ សង្កាត់លេខ ១ ទីរួមខេត្តស្វាយរៀង ។ ឪពុកឈ្មោះ អ៊ុក យន់ "ស" ម្តាយឈ្មោះ នង កេត "ស" ប្រពន្ធឈ្មោះ ទេព បុប្ផា ។

កម្មវត្ថុបណ្តឹង : ប្តឹងទាមទារដីភូមិ ។

បានឃើញបណ្តឹងសាទុក្ខលេខ ១៧០ ចុះថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ១៩៩៦ របស់ឈ្មោះ លោក ឈូ រុន ប្តឹងមិនសុខចិត្តនឹងសាលដីការបស់សាលាឧទ្ធរណ៍ទាំងមូល ។ល។

បានឃើញសំណុំរឿងរដ្ឋប្បវេណីលេខ ២១៩ ចុះថ្ងៃទី ១៨ ខែ តុលា ឆ្នាំ ១៩៩៦ របស់តុលាការកំពូល ។

តាមពាក្យបណ្តឹងចុះថ្ងៃទី ០២ ខែ កក្កដា ឆ្នាំ ១៩៩៣ របស់ឈ្មោះ ឈូ រុន ប្តឹងរំលោភឈ្មោះ អ៊ុក សុភាព រុះរើផ្ទះចេញពីដីរបស់ខ្លួន ដោយសំអាងហេតុថា កាលពីខែ ១១ ឆ្នាំ ១៩៨៩ ឈ្មោះ អ៊ុក សុភាព និងប្រពន្ធឈ្មោះ ទេព បុប្ផា បានមកសុំដីភូមិរបស់ខ្លួនដែលនៅទំនេរដើម្បីស្នាក់នៅជាបណ្តោះអាសន្ន ដោយកាលនោះប្រធានមន្ទីរឧស្សាហកម្មបានដេញឈ្មោះនេះឈប់អោយស្នាក់នៅ ។ កាលមកសុំស្នាក់នៅលើដីខ្លួននេះ ភូមិ ឃុំ បានអោយឈ្មោះ អ៊ុក សុភាព ធ្វើកិច្ចសន្យាផ្ទាល់ខ្លួន ឈ្មោះ អ៊ុក សុភាព ក៏ធ្វើកិច្ចសន្យាសុំស្នាក់នៅបណ្តោះអាសន្នដោយបញ្ជាក់ថា មិនយកដីនេះធ្វើជាកម្មសិទ្ធិទេ ។

បានឃើញសាលក្រមរដ្ឋប្បវេណីលេខ ២២ ចុះថ្ងៃទី ២៩.៥.១៩៩៥ របស់តុលាការខេត្តស្វាយរៀង ដែលមានខ្លឹមសារនៃសេចក្តីសំរេចដូចតទៅ :

១ - ទទួលពាក្យបណ្តឹងរបស់ឈ្មោះ ឈូ រុន "ដើមចោទ" ទុកជាត្រឹមត្រូវតាមទំរង់ និងគតិច្បាប់ ។

២ - ប្រគល់ដីកើតហេតុទំហំ ១.៧៣, ៥៩ ម៉ែត្រក្រឡា ស្ថិតនៅភូមិទី ៦ សង្កាត់លេខ ១ ទីរួមខេត្តស្វាយរៀង មានព្រំប្រទល់ ខាងជើងទល់នឹងឈ្មោះ ឈូ រុន, ខាងត្បូងទល់នឹងផ្លូវប្រេក - ខាងកើតទល់នឹងផ្លូវប្រេក, ខាងលិចទល់នឹងឈ្មោះ កែន សាន អោយទៅឈ្មោះ ឈូ រុន "ដើមចោទ" វិញចាប់តាំងពីថ្ងៃនេះតទៅ ។

៣ - បង្គាប់អោយឈ្មោះ អ៊ុក សុភាព "ចុងចម្លើយ" រុះរើផ្ទះចេញពីដីកើតហេតុនេះ តែត្រូវអោយឈ្មោះ ឈូ រុន ប្រគល់ប្រាក់ ២.០០០៛ អោយឈ្មោះ អ៊ុក សុភាព វិញ ក្នុងរយៈពេល ២ ខែ ចាប់តាំងពីថ្ងៃនេះតទៅ ។

៤ - សំរេចអោយឈ្មោះ អ៊ុក សុភាព បង់ប្រាក់ប្រដាប់ក្តី ពន្ធចុះបញ្ជីក្តី និង ពន្ធពិន័យ ១.៨០០៛ រង្វាន់ក្រឡាបញ្ជីការពិបប្រាក់ ២០០៛ រង្វាន់អ្នកប្រគល់ដីការកោះ ៥.០០០៛ - បូករួម ៧.០០០៛ ។ ប្រាក់នេះបានកាត់យកពីប្រាក់ ៧.០០០៛ ដែលដើមចោទបានបង់ទុករួចហើយ